# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់លើការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតឱ្យសេវាករ ឡាយ វ៉េងឃាង និងសេវាករ ញ៉ៀម សុធារី ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំព្រៃកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និងនៅឃុំព្រៃកតាកូវ និងឃុំស្វាយជ្រំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ឡាយ វ៉េងឃាង និងសេវាករ ញ៉ៀម សុធារី ឱ្យបានជ្រាបថា ដោយសារស្ថានភាពតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ និងដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករធ្វើសេវាកម្មអគ្គិសនីមានអត្រាថ្លៃលក់ត្រឹមត្រូវ និងយុត្តិធម៌ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាត់តាំងមន្ត្រីជំនាញចុះទៅកាន់ទីតាំងធ្វើសេវាកម្មអគ្គិសនីរបស់សេវាករទាំង២ ដើម្បីពិនិត្យវាស់អត្រាប្រើប្រាស់ប្រេង បរិមាណថាមពលផលិត និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនី ដោយបានអញ្ជើញតំណាងសាលាឃុំ និងតំណាងអ្នកប្រើប្រាស់នៅក្នុងតំបន់របស់សេវាករទាំង២ចូលរួមជាអ្នកអង្កេតការណ៍ រួចយកមកធ្វើការសិក្សាថ្លៃដើមអគ្គិសនី និងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការធ្វើសេវាកម្មអគ្គិសនីនេះ ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី។ តាមស្ថានភាពតម្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ ដូច្នេះដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនី និងស្ថានភាពហិរញ្ញវត្ថុរបស់សេវាករទាំង២ និងដើម្បីឱ្យមានយុត្តិធម៌ និងសមធម៌ រវាងអ្នកប្រើប្រាស់អគ្គិសនី និងអ្នកធ្វើសេវាកម្មផង អាជ្ញាធរអគ្គិសនីកម្ពុជាបានគណនាថ្លៃដើមអគ្គិសនី និងគ្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដូចក្នុងតារាងខាងក្រោម ÷

| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **360** | **425** | **490** | **555** | |
|---|---|---|---|---|---|
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងឃាង (រៀល/គ.វ.ម៉) | 1,616 | 1,724 | 1,832 | 1,940 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉ៀម សុធារី (រៀល/គ.វ.ម៉) | 1,474 | 1,583 | 1,691 | 1,799 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **1,900** | **2,000** | **2,100** | **2,200** | |

| | | | | | |
|---|---|---|---|---|---|
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **620** | **685** | **750** | **815** | |
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងយាង (រៀល/គ.វ.ម៉) | 2,048 | 2,157 | 2,265 | 2,373 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉េម សុធារី (រៀល/គ.វ.ម៉) | 1,907 | 2,015 | 2,123 | 2,231 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,300** | **2,400** | **2,500** | **2,600** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **880** | **945** | **1,010** | **1,075** | |
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងយាង (រៀល/គ.វ.ម៉) | 2,481 | 2,589 | 2,697 | 2,805 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉េម សុធារី (រៀល/គ.វ.ម៉) | 2,340 | 2,448 | 2,556 | 2,664 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,700** | **2,800** | **2,900** | **3,000** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,140** | **1,205** | **1,270** | **1,335** | |
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងយាង (រៀល/គ.វ.ម៉) | 2,914 | 3,022 | 3,130 | 3,238 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉េម សុធារី (រៀល/គ.វ.ម៉) | 2,772 | 2,880 | 2,988 | 3,097 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,100** | **3,200** | **3,300** | **3,400** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,400** | **1,465** | **1,530** | **1,595** | |
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងយាង (រៀល/គ.វ.ម៉) | 3,346 | 3,454 | 3,562 | 3,671 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉េម សុធារី (រៀល/គ.វ.ម៉) | 3,205 | 3,313 | 3,421 | 3,529 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,500** | **3,600** | **3,700** | **3,800** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,660** | **1,725** | **1,790** | **1,855** | |
| ថ្លៃដើមអគ្គិសនីសេវាករ ឡាយ វ៉េងយាង (រៀល/គ.វ.ម៉) | 3,779 | 3,887 | 3,995 | 4,103 | |
| ថ្លៃដើមអគ្គិសនីសេវាករ ញ៉េម សុធារី (រៀល/គ.វ.ម៉) | 3,637 | 3,745 | 3,854 | 3,962 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,900** | **4,000** | **4,100** | **4,200** | |

តាមតារាងខាងលើ នៅពេលថ្លៃប្រេងម៉ាស៊ូតឡើងថ្លៃ ឬចុះថ្លៃតាមចំនួនកំណត់ក្នុងតារាងខាងលើ ពេលនោះ អត្រាថ្លៃលក់អគ្គិសនីរបស់សេវាករទាំង២អាចឡើង ឬចុះតាមចំនួនកំណត់ក្នុងតារាងខាងលើ ។

ដើម្បីឱ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឱ្យក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសាធារណជនទាំងអស់មេត្តាពិនិត្យ និងផ្តល់មតិលើឯកសារគណនា វិភាគ វាយតម្លៃកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករទាំង២ ជាតារាងថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូត ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០** ។ ក្រោយថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ឯកសារគណនា វិភាគវាយតម្លៃបញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករទាំង២ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តលើតារាងបញ្ជីថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ស ្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឱ្យ **ការផ្តល់យោបល់មកឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងអាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៩៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ហើយសូមឱ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឱ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកធ្វើសេវាកម្មអគ្គិសនីផង ។**

ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់សេវាករទាំង២ ឯកសារគណនា វិភាគ វាយតម្លៃថ្លៃដើមអគ្គិសនី តារាងបញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូតលម្អិត ព្រមទាំងល័ក្ខខ័ណ្ឌសម្រាប់អនុវត្តយន្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូត ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៩៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ........................................................................................ សម្រាប់សាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**